ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១២

ខែ ១

កុងស៊ីយសេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស. ២៤៨២
គ. ស. ១៩៤០

IOTHÈQUE
TIONALE
AMBODGE

# អារម្ភកថា

# នៃទស្សនាវដ្ដីកម្ពុជសុរិយា

## ឆ្នាំទី១២ គ្រិស្តសករាជ១៩៤០

ទស្សនាវដ្ដីកម្ពុជសុរិយា ដែលលោក អ្នកកំពុងតែចាប់មើលសេចក្ដីតទៅខាងមុខនេះ យើងសូមជំរាបទុកជាមុនថា រឿងរ៉ាវផ្សេងៗ ដែលយើងបានរៀបចំផ្សំឡើងជាថ្មីនេះ គង់ធ្វើឲ្យលោក-អ្នកដែលធ្លាប់មើលទស្សនាវដ្ដីរបស់យើងពីដើមនឹកចំឡែកក្នុងចិត្តខ្លះមិនខានថា យីអើ! ទស្សនាវដ្ដីឆ្នាំថ្មីនេះ ថ្មីទាំងរូបរាង ថ្មីទាំងសេចក្ដីដែលចុះផ្សាយ គឺពីដើមមកកំណត់ចេញផ្សាយ ៣ ខែម្ដង មួយឆ្នាំមានត្រឹម ៤ ក្បាលប៉ុណ្ណោះ ដល់មកឆ្នាំ ១៩៤០ នេះជាដើមទៅ បែរជាកែប្រែកំណត់នេះជាថ្មី គឺចេញផ្សាយរាល់ខែវិញ ដើម្បីឲ្យបានទាន់ចិត្តអ្នកមើលទស្សនាវដ្ដីនេះរាល់គ្នាៗ មួយវិញទៀត ពីដើមមកទស្សនាវដ្ដីនេះច្រើនតែចុះផ្សាយគតិធម៌ មានគតិលោកបន្តិចបន្តួច តាំងអំពីឆ្នាំនេះជាដើមទៅ យើងនឹងចុះផ្សាយគតិលោកឲ្យបានច្រើនបំផុតដោយយើងយល់ថា កម្ពុជរដ្ឋរបស់យើងវេលានេះ ពុទ្ធសាសនិកជនខ្លះទៅមានចំណេះចេះដឹងគតិធម៌ល្មមសមគួរហើយដែរ ទាំងសៀវភៅផ្សេងៗ ដែលមានបោះពុម្ពទាំងអម្បាលម៉ាណក៏សុទ្ធតែរឿងគតិធម៌ស្ទើរតែទាំងអស់ ចំណែកឯក្បួនច្បាប់គតិលោកមានចំនួនស្ដួចស្ដើងណាស់ ហេតុនេះទើបយើងយល់ថា សេចក្ដីកែប្រែដែលបានថ្លែងមកនេះ

គង់នឹងបានសម្រេចជាហិតានុហិតប្រយោជន៍ដល់ប្រជាជនជាតិខ្មែរខ្លួទៅ ដូចមានគោលសំខាន់ៗ ដែលយើងបានបោះពុម្ពផ្សាយក្នុងប្រូក្រាមដូន ដំណើររបស់ព្រះរាជបណ្ណាល័យ កាលពីឆ្នាំ ១៩៣៩ នេះស្រាប់ ។

ឯគតិធម៌នោះ គង់តែមានបោះផ្សាយក្នុងទស្សនាវដ្តីនេះជាលំដាប់ៗទៅដែរ តែនឹងជ្រើសរើសរកតែត្រង់ដែលមាននិយាយពីគតិធម៌ប្លែកៗ ដែលពុទ្ធសាសនិកជនជាតិយើងមិនសូវបានស្គាល់ដឹងឮកល់គ្នាប៉ុណ្ណោះ ក្រៅពីនេះ នឹងចុះផ្សាយខាងគតិលោកទាំងអស់ ទុកគតិធម៌ប្រគល់ឲ្យសាសនកិច្ចានុក្រមបោះពុម្ពផ្សាយដោយឡែក ដោយមិនបាច់ឲ្យមានរឿងគតិលោកចូលនៅប្រឡូកប្រឡំផង ។

ការរៀបចំផ្សំគ្រឿងតាមទំនងនេះ ដើម្បីដំរូវទៅតាមចំណង់របស់លោកអ្នកជាវមើលទស្សនាវដ្តីទាំងពីរមុខ តាមសេចក្តីស្ម័គ្រចិត្តរៀងខ្លួន ៗ មុននឹងបញ្ចប់សារម្ភកថាដោយសង្ខេបនេះ សូមរំឭកអស់លោក-អ្នក ដែលបានមើលទស្សនាវដ្តីនេះជួយផ្សាយដំណឹងនេះដល់លោក-អ្នកដទៃៗតទៅទៀត ដើម្បីជាប្រយោជន៍ដល់ប្រជាជនរួមជាតិជាមួយគ្នា ដោយការនាំគ្នាជួយទំនុកបំរុងអក្សរសាស្ត្ររបស់ជាតិខ្មែរឲ្យបានចំរើនទាន់កាលសម័យនឹងគេឡើង ក្រុមអ្នកតែងរឿងចុះផ្សាយ សូមថ្លែងសេចក្តីអរគុណទុកជាមុន ៗ

ទេពរង្សី

# បញ្ជីរឿង


១ — សេចក្ដីផ្ដើមក្នុងការធ្វើសាកលប្រវត្តិសាស្ត្ររបស់អ្នកមហា ញ៉ុក-ថែម . . . . ៣

២ — សិក្ខាកាមកថា របស់ទេមរង្សី . . . . . . . . . . . . . . . . . . . ១៥

៣ — ដំណឹងស្ទើង-៦ របស់លោកអគ្គលេខាធិការ នៃពុទ្ធសាសនបណ្ឌិត្យ . . . . ២១

៤ — បកិណ្ណកកថា របស់ទេមរង្សី . . . . . . . . . . . . . . . . . . . ២៩

៥ — ប្រជុំពាក្យកាព្យកាគទី ៣ (តពីឆ្នាំទី ១១ នឹងចប់) ពាក្យកាព្យសង្វាស ជារបស់
ផ្សេងៗកោហារក្ន . . . . . . . . . . . . . . . . . . . . . . . . ៣៩

៦ — រឿងព្រេងខ្មែរ រឿងបុរសកំសត់ដេញទៅឆ្ងាយ . . . . . . . . . . . . . ៤៥


## រូបក្រការឿង


ទេវរូបខាត របស់ជាទុ ដែលព្រាយស្រុក ស្រុកខ្លួន ធ្វើមកជូនព្រះរាជបណ្ណាល័យកម្ពុជា កាលពីខែឧសភា ឆ្នាំ ១៩៣៩ . . . . . . . . . . . . . ០

# TABLE DES MATIÈRES


| | Pages. |
|---|---|
| 1° Exposé sommaire sur l'histoire universelle par Maha Nhok-Thêm | 3 |
| 2° Curiosité des hommes par khemararansi | 15 |
| 3° Informations Diverses | 21 |
| 4° Pakinnakakatha ou faits divers par khemararansi | 29 |
| 5° Recueil de Poèmes cambodgiens 3e partie (suite et fin) | 35 |
| 6° Conte et légende populaires cambodgiens inédits: | |
| Un homme pauvre qui fait le commerce | 45 |


HORS TEXTE :


| | |
|---|---|
| Porte-écrans en forme de Naga offerts par Thao Kou de Khong à la Bibliothèque Royale. Août 1939 | 1 |



នេះជើងម្លិតរូបនាគ
ជាវត្ថុធ្វើអំណោយ

# សេចក្តីផ្តើម

## ក្នុងការធ្វើប្រវត្តិសាស្ត្រនានាជាតិ

កាលបើលោក-អ្នកពិនិត្យមើលបំណងដើមខាងលើនេះ គង់តែនឹងជ្រាបច្បាស់ថា រឿងរ៉ាវដែលនឹងបើកមើលជាលំដាប់ ៗ តទៅខាងមុខនេះ មិនមែនជាសេចក្តីខ្លី ៗ មើលឆាប់ចប់ទេ ដ្បិតគោលពណ៌នាអំពីពង្សា-វតាររបស់នានាជាតិក្នុងលោក គង់មានសេចក្តីសារសព្វវែងឆ្ងាយទូលាយលន្លង់លន្លោច ហាក់ដូចជាធ្វើដំណើរទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាល ទម្រាំតែដើរដល់ទៅចុងផ្លូវតោងប្រើពេលវេលាជាយូរអង្វែង ៗ កាលបើលោក-អ្នកនឹកដូច្នេះ គង់តែនឹងមានចិត្តធុញទ្រាន់មិនចង់ចាប់រឿងរ៉ាវអស់នេះពិនិត្យមើលទៅខាងមុខទៀត មុខតែនឹងទម្លាក់ចោលត្រឹមណោះហើយ វៀរលែងតែលោកអ្នកដែលត្រូវការចង់ចេះចង់ជ្រាបរឿងរ៉ាវរបស់ប្រទេសផ្សេង ៗ ដោយស្ម័គ្រចិត្តប៉ុណ្ណោះ ទើបហ៊ានដើរផ្លូវឆ្ងាយដាច់ស្រយាលនេះរហូតដល់ចុងផ្លូវសមតាមបំណងបាន ។

តែយើងសូមអង្វរលោក-អ្នកបន្តិចសិន កុំអាលទម្លាក់ចោលដោយរួសរាន់ ព្រោះការរៀបរៀងពង្សាវតារលោកឡើងនេះ យើងមានបំណងឲ្យបានប្រយោជន៍ជា ២ ផ្លូវ គឺត្រូវការឲ្យបានប្រយោជន៍ទាំងអ្នកត្រូវការមើលដោយសង្ខេបឬដោយសេចក្តីពិស្តារ តែនឹងបានសម្រេចជាប្រ-

យោជន៍ដល់លោក-អ្នក ត្រឹមណា យើងមិនទាន់ហ៊ានទទួលក៏បានទេ គ្រាន់តែយើងសូមឲ្យលោកអ្នកជឿចុះថា យើងមានបំណងល្អបំផុតដល់ប្រជា-ជនរួមជាតិជាមួយគ្នា ដោយមានមេត្រីចិត្តចង់ចែកផ្សាយចំណេះវិជ្ជានឹងរឿងកិច្ចការនានាដល់មិត្តរួមជាតិប៉ុណ្ណោះ ដោយយល់ថា អស់លោក-អ្នកជាញាតិមិត្តរួមជាតិជាមួយគ្នាបំពួកខ្លះ ដែលមិនទាន់បានជ្រាបរឿងកិច្ចការផ្សេងៗក្នុងពង្សាវតាររបស់នានាជាតិនោះ នោះមានចំនួនច្រើនណាស់ដែរ ប្រសិនបើគំនិតនេះបែរជាខុសទៅវិញ សូមអស់លោក-អ្នកអភ័យទោសឲ្យបានផង ឬមានមេត្តាចិត្តពន្យល់ទៅឲ្យយើងៗ សូមអរគុណចំពោះមេត្រីចិត្តរបស់លោក នឹងសូមបង្អោនកាយទទួលយកសេចក្ដីពន្យល់របស់លោកដោយសេចក្ដីគោរព ។

ឯវិធីរៀបរៀងពង្សាវតារនេះ យើងនឹងរៀបរៀងចែកពេលកាលយុគតាមសម័យដូចមានរបៀបតទៅនេះ :

## ក — វិធីបែងកាលសម័យតាមប្រវត្តិសាស្ត្រ

វិធីនេះមាន ២ ប្រការ គឺបែងចែកជាសម័យមុនមានប្រវត្តិសាស្ត្រ នឹងសម័យមានប្រវត្តិសាស្ត្រហើយប្រការ ១ ចែកចេញជាសម័យចាស់, សម័យកណ្ដាល, សម័យថ្មី នឹងសម័យបច្ចុប្បន្នប្រការ ១ ។

ប្រការ ១ ខាងដើមនោះ គប្បីយល់ថា មនុស្សជាតិនេះបានកើត

ឡើងក្នុងលោកនេះហើយ ប្រមាណ ១ សែនឆ្នាំ តែចំណែកដែលមាន ប្រវត្តិសាស្ត្រឬពង្សាវតារល្មមយកមកភ្ជាប់គ្នាជាកងកៅល្មមប្រើការបាន នោះមិនហួសពី ៧ ពាន់ឆ្នាំដែលកន្លងមកនេះទេ តាមទំនងនេះឃើញថា យើងបានដឹងរឿងរ៉ាវរបស់មនុស្សជាតិដងគ្នាតិចពេក មិនសមនឹងកំណើត របស់មនុស្សជាតិដែលកើតមកហើយជាអន្លើនឆ្នាំ ៗ

ហ្លួងវិចិត្រវាទការ រដ្ឋមន្ត្រី នៃប្រទេសថៃ ជាអ្នកតែងពង្សាវតារ លោកមកជាភាសាថៃ ហើយធ្វើជាគ្រូបង្រៀនពង្សាវតារនានាជាតិនៅ មហាវិទ្យាល័យ បានពោលក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់លោកថា អ្នកប្រាជ្ញពង្សាវតារទាំងឡាយ បានបែងចែកប្រវត្តិសាស្ត្រនេះជា ២ ចំណែក គឺចំណែកមុនមានប្រវត្តិសាស្ត្រ និងចំណែកមានប្រវត្តិសាស្ត្រហើយ ។ ឯចំណែកមុនមានប្រវត្តិសាស្ត្រនោះ មានអ្នកប្រាជ្ញពង្សាវតារជាច្រើន នាក់បានរៀបរៀងធ្វើរឿងរ៉ាវឡើង តែកម្រមានល័ក្ខខ័ណ្ឌមាំមួន គោង តែមានសេចក្តីសន្និដ្ឋានជាត្រឹមប្រកបសេចក្តីអធិប្បាយ កាលបើមានគំនិតគិតឃើញដោយខ្លួន សេចក្តីសន្និដ្ឋានក៏ដោយខ្លួន សេចក្តីអធិប្បាយក៏ដោយខ្លួន ទើបមានការយល់ទាស់គ្នា ខ្វែងគ្នាជានិច្ច មិនអាចនឹងវិនិច្ឆ័យបានថា អ្នកណាខុសអ្នកណាត្រូវទេ ដូចជាមានប្រស្នាមួយសួរថា មនុស្សកើតមកអំពីអ្វី? ទុកជាការកេតស្តាន់មកប្រកបសេចក្តីពន្យល់

យ៉ាងណា ក៏នៅតែមានចំណុចដែលគ្នាមិនបេះបិទមិនបេះអស់ឡើយ ។ តាម្ល ដោយពិត ការស្រាវជ្រាវរករឿងរ៉ាវរបស់មនុស្សមុនសម័យ ៧.០០០ ឆ្នាំឡើងទៅនោះ មិនមែនធ្វើបានដោយងាយទេ ទើបត្រូវតែលើកទុកដោយឡែក គ្រាន់តែនាំគ្នាមកសិក្សាក្នុងសម័យដែលមានជម្រាបលក្ខ-ខណ្ឌប៉ុណ្ណោះ ជីវិតយើងនៅតែមិនវែងល្មមធ្វើឱ្យយើងសិក្សាបានល្អិតល្អមែន ៗ នោះផង ។

ប្រការទី ២– ទំនាយតាំងពីសម័យមានប្រវត្តិសាស្ត្រ អ្នកប្រាជ្ញពង្សាវតារបានចែកចេញជា ៤ សម័យគឺ (១) សម័យបុរាណព្រេងនាយចាប់តាំងពី ៤.៥០០ ឆ្នាំ មុនពុទ្ធសករាជ (មុនគ្រិស្តសករាជ ៥០០០ ឆ្នាំ) រហូតមកដល់ពុទ្ធសករាជ ៩៣៨ ឆ្នាំ (គ្រិស្តសករាជ ៤៣៨) ជាពេលជាង ៥០០០ ឆ្នាំ (២) សម័យកណ្ដាល តាំងអំពីពុទ្ធសករាជ ៩៣៩ ដល់ពុទ្ធ-សករាជ ២.០៤១ ជាពេល ១.១០៣ ឆ្នាំ (៣) សម័យថ្មី ចាប់តាំងពីពុទ្ធ-សករាជ ២.០៤២ ដល់ពុទ្ធសករាជ ២.៣៣២ ជាពេល ២៩១ ឆ្នាំ និង (៤) សម័យបច្ចុប្បន្ន តាំងអំពីពុទ្ធសករាជ ២.៣៣៣ រហូតដល់សព្វថ្ងៃនេះ ។ រីឯវែងសម័យជារយៈៗ តាមទំនងនេះមានហេតុផលជាសមគួរពិតៗ គឺក្នុងសម័យនីមួយ ៗ សេចក្ដីចំរើនគំនិតគិតគូរ និងហេតុភេទរបស់លោករមែងប្រែប្រួលជាច្រើនណាស់តាមយុគតាមសម័យនោះៗ ។

“ក្រៅនេះ”, អញ្ញ “ដទៃ, ឯទៀត”; អញ្ញតរ “ណាមួយ, ម្នាក់”, អញ្ញតម “ណាមួយ, ម្នាក់” ។ ឯ ឥតរេតរ ទីង អញ្ញោញ្ញ “ដទៃនឹងដទៃ, ទៅវិញទៅមក, គ្នានឹងគ្នា” ទាំងពីរសព្ទនេះ ប្រើបានចំពោះតែត្រង់ឯកវចនៈតែម្យ៉ាង. ១. តេ ជនា ឥតរេតរំ ទុស្សន្តិ. – អញ្ញោញ្ញស្ស គរុ, “ជនពីរនាក់នោះ ស្អប់គ្នា ទៅវិញទៅមក, – ជាសត្រូវ ដល់គ្នានឹងគ្នា ឬ ជាសត្រូវនឹងគ្នាទៅវិញទៅមក” ។

ខ) គុណសព្ទទាំងឡាយ ដែលមានវិធីបំបែកដូចគ្នានឹងសព្វនាម ទាំងអស់ដែរ វៀរលែងតែ នបុំ. ត្រង់ ប. ទុ. ឯក. ជា អំ ម៉ នោះគឺ សព្ទដូចមានតទៅនេះ :

សព្វ, “ទាំងពួង” ប. ឯក. បុំ. សព្វោ, នបុំ. សព្វំ, ស្ត្រី. សព្វា ។ល។

វិស្ស, “ទាំងពួង” ប. ឯក. បុំ. វិស្សោ, នបុំ. វិស្សំ, ស្ត្រី. វិស្សា ។ល។

ឯក, “មួយ, ពួកមួយ” ប. ឯក. បុំ. ឯកោ, នបុំ. ឯកំ, ស្ត្រី. ឯកា ។ល។ ប. ពហុ. បុំ. ឯកេ (ជនទាំងឡាយ) ពួកមួយ ។

គ) គុណសព្ទទាំងឡាយ ដែលមានវិធីបំបែកតាមទំនងនៃសព្វនាម ដែរ ប៉ុន្តែតាមដោយធម្មតា ប្រើនតែបំបែកដូចជានាមសព្ទ ឬគុណសព្ទ ជាអការន្ត សព្ទទាំងនោះ គឺ :

ឧត្តរ, "ប្រសើរ," ឧត្តម, "ឧត្តម, ខ្ពង់ខ្ពស់"; អធរ "ថោកទាបជាង" អធម, "ថោកទាបបំផុត"; បុរិ "ដែលមាន ឬដែលកើតក្នុងកាលមុន"; បរ, "ដទៃ"; ស្វ "របស់ខ្លួន, ជារបស់ខ្លួន" ។

៥. គុណសព្ទទាំងឡាយ ដែលកើតមកពីសព្វនាម (ល. ៨០-៨១-៨២) ដោយអាស្រ័យនឹងប្រត្យយ វន្តុ ហៅថាគុណសព្ទក្លាយ គុណ-សព្ទនោះ គឺ:

ក) យាវន្តុ "ប៉ុនណា, (ធំ) ប៉ុនណា, (មានទំហំ) ប៉ុនណា", តាវន្តុ "ប៉ុណ្ណោះ, (ធំ) ប៉ុណ្ណោះ, (មានទំហំ) ប៉ុណ្ណោះ (ម. ល. ៦៧); នបុំ. កិ. វិ: យាវត "(យូរ) ដរាបណា, ត្រឹមណា", តាវត "(យូរ) ដរាបនោះ, ត្រឹមនោះ" (បើមានកែ យាវត ប្រែថា "រីឯ, ចំណែកឯ, ចំណែកខាង...")

ខ) តទ-វន្តុ = តទ្វន្តុ "មានយ៉ាងនោះ, មានដូចជា...នោះ, ប្រហែលដូចជា...នោះ" (ម. ល. ៦៨); នបុំ. កិ. វិ. តទ-វត = តទ្វត "តាមបែបយ៉ាង, តាមវិធី..." ។

(ប្រត្យយ វត ដែលភ្ជាប់នឹង នបុំ. កិ. វិ. ខាងលើនេះ, កាល

បើយកមកភ្ជាប់នឹងនាមសព្ទវិញ គេអាចប្រើដូចនិបាតសព្ទ ជាឧបមានត្ថ ប្រែថា "ដូច..." ឧ. ទេវ-វត៌, "ដូចជាទេវតា", មនុស្ស-វត៌ "ដូចជាមនុស្ស", អហិ-វត៌ "ដូចជាពស់"; ចំណែកគុណសព្ទខ្លះ ក៏អាចប្រកបដោយប្រត្យយ វត៌ នេះដែរ ប្រើបានដូចគ្នា: បុរិ-វត៌ "ដូចក្នុងកាលមុន") ។

គ) យទីយ, "របស់អ្នកណា", តទីយ "របស់អ្នកនោះ" (ម. ល. ៧៨ ត្រង់ ល. ៤) ។

ឃ) កតិ(១), "មានប៉ុន្មាន"; យតិ, "ប៉ុនណា"; តតិ, "ប៉ុននោះ".– សព្ទទាំងនេះ ប្រើចំពោះតែពហុវចន, វេលាបំបែកដូចគ្នាទាំង ៣ លិង្គ ឥតមានប្រែប្រួលផ្លាស់ប្តូរឲ្យផ្សេងគ្នាទៅតាមលិង្គឡើយ ។ នឹងបំបែកតែ កតិ ១ ទុកជាបែបយ៉ាង: ប្រ. កតិ, ទុ. កតិ, ត. កតិភិ, ច. កតិក្យសិ, ប. កតិក្យសិ, ឆ. កតីនាមិ, ស. កតិសុ ។

ឯ យតិ, តតិ បំបែកដូចគ្នានឹង កតិ ខាងលើនេះដែរ ។

---

១ បើជា កតិបយ, ប្រែថា "មានប៉ុន្មាន" ដូចគ្នា តែប្រើបានទាំង ៣ វចន វេលាបំបែក ក៏ផ្លាស់ប្តូរទៅតាមលិង្គទាំង ៣ : ប្រ. ឯក. បុំ. កតិបយសិ; — ស្ត្រី. កតិបយា; — នបុំ. កតិបយមិ ។ល។

ដំណើរផ្សេង ៗ

# ចំរៀងក្នុងឥណ្ឌៀ

យើងគិតថា បណ្ដាអ្នកមើលទស្សនាវដ្ដីរបស់យើង គង់ចង់ដឹងរឿងចំរៀងរបស់ប្រជាជនឥណ្ឌា ដែលគេតែងនាំគ្នាច្រៀងនោះខ្លះដែរ ពួកនេះមានទៅក្នុងចំណោមខេត្តនៃប្រទេសឥណ្ឌៀកណ្ដាល ឯបទចំរៀងរបស់គេនោះ ពេញដោយសេចក្ដីពិរោះរាប់ចិត្តទឹងមានគំនិតត្រឹមត្រូវផង ។

ឯបទចំរៀងនេះមាន ៦ បទដែលយើងស្រង់យកតែសេចក្ដីសំខាន់ៗ មកពន្យល់ដល់អ្នកមើលទស្សនាវដ្ដីនេះ ។

— ១ —

ផ្លែស្វាយខ្ញុំសម្រាប់ប្រើជាគ្រឿងបរិភោគ ឯសេចក្ដីមេត្តាត្រូវគេរក្សាទុកជាទីពឹង ។

— ២ —

ធ្មេញរបស់អ្នកស្អាតដូចជាពណ៌ប្រាក់ ហើយមុខរបស់អ្នកក៏ស្រស់ប៉ប្រឹម គួរជាទីទស្សនា ៗ អ្នកនេះហើយដែលធ្វើឲ្យចិត្តខ្ញុំគាំងគាំងកិស្សង់ ប៉ុន្តែតាមពិតនោះដួងចិត្តរបស់អ្នកមិនមានមួលសុចរិតទៀងត្រង់ទេ ៗ ហើយជីវិតរបស់ខ្ញុំនៅតែភាប់ពាក់នៃសេចក្ដីទុក្ខជាដរាប ។

— ៣ —

កាលណាអ្នកព្រាត់ប្រាសចាកសំឡាញ់ម្នាក់ទៅ អ្នកអាចរកមកជំនួសវិញបាន ។ ប៉ុន្តែកាលណាអ្នកព្រាត់ប្រាសចាកម្ដាយរបស់អ្នកទៅ កាលណោះ អ្នកនឹងនឹកឃើញតែម្ដង ។ កាលបើគំនិតរបស់អ្នកងងឹត (ទាល់គំនិត) មានតែសំឡាញ់ជួយបំភ្លឺ ហេតុនេះ ទើបអ្នកត្រូវតែទៅស្វែងរកទាំងយំនៅកណ្ដាលពិភពនេះ ។

— ៤ —

កាលទូតរបស់មច្ចុរាជមកដល់ផ្ទះគឺកងកាយ ដែលបានចាត់ការថែទាំយ៉ាងម៉ឺងម៉ាត់ ប៉ុន្តែទូតរបស់មច្ចុរាជនៅតែមកឈរចាំនៅមាត់ទ្វារ ហើយក៏ទឹងបិទទ្វារគ្រប់មួយរំពេច នាំឱ្យ:

— ម្ដាយទ្រហោយំ អហ៊ឺ-អហ៊ឺ-អហ៊ឺ

— ប្អូនស្រីយំសោកដល់បងប្រុស ៦ ខែ

— ប្រពន្ធយំសោកដល់ប្ដីត្រឹម ៣ ថ្ងៃ

ហើយពីនោះទៅទើបប្រទះនឹងបុរសថ្មីទៀត ។

— ៥ —

យើងរាល់គ្នាតែងជាប់នៅក្នុងសំណាញ់ ពោលគឺ:

— ៦៣ —

សេចក្តីស្នេហាចំពោះបុគ្គលដែលត្រូវជា ម្តាយឪពុក

— បងប្អូនប្រុស

— បងប្អូនស្រី

— ប្តីប្រពន្ធ

— ៦ —

ស្បែកជើងគេធ្វើឡើងសម្រាប់ពាក់ទៅដើរ សត្វពាហនៈ មានប្រយោជន៍សម្រាប់អ្នកជិះ ប៉ុន្តែម្តាយឪពុករើសប្តីមកជាគូនោះ មិនមែនបានជាប់មកខ្ញុំទេ ស្រេចទៅជោគជតារបស់ខ្ញុំ តែងជាប់មកនឹងខ្លួន តាំងអំពីព្រេងនាយ ៗ ឱះ ឱ! ឱះ ឱ! បើពោលតាមពិត តើវាមានប្រយោជន៍តិចទេឬអ្វី? ជ្រូតជីវិត ទុកដូចជាដុំពពុះទឹក គ្រាន់តែត្រូវខ្យល់ផាត់មកដំបូងក៏បែកទៅហើយ ៗ

*

* *

## អំពីជាតិសម្រែ

លោកបាក់ផាត់ជាគ្រូពេទ្យសត្វនៅខេត្តបាត់ដំបង មុនលោកនឹងចេញទៅឈប់សម្រាក លោកបានបង្ហើយបែបបង្រៀនពាក្យជាតិសម្រែមួយ ដែលមានប្រយោជន៍ច្រើន ៗ នៅក្នុងសេចក្តីអស់នោះ មាននិយាយ

ពីបម្រើនឹងវិធីសម្រាលកូនរបស់ជាតិពារ (Pear) សឹងមានរបៀបបែបផែនល្អ ។ ការងាររបស់លោកនេះមានប្រយោជន៍យ៉ាងធំដល់មនុស្សទូទៅ ដែលពារ់កែគោលចារិកអំពីមនុស្សជាតិផ្សេងៗ នៅស្រុកខ្មែរ ។

មេបទបង្រៀនជាភាសាបារាំង- ខ្មែរ- សៀម (ទាំង ៣ ភាសានេះ) កាលបើបានបោះពុម្ពឡើង នឹងសម្រេចជាការងារដ៏ប្រសើរមួយរបស់លោកគ្រូពេទ្យនោះ ។

* * *

## អំពីការសិក្សាភាសាបាលី

ក្នុងទស្សនាវដ្ដីមហាពោធិប្រចាំខែណូវែម្ប្រ៍ ១៩៣៩ មានសេចក្ដីផ្សាយដំណឹងថា នៅមហាវិទ្យាល័យកល់គុត្តានឹងបមបៃ នឹងមហាវិទ្យាល័យឯទៀតៗ នៅប្រទេសឥណ្ឌា មានចំនួនអ្នកសិក្សាជាច្រើនពាន់ ដែលនាំគ្នាសិក្សាក្នុងថ្នាក់បង្រៀនបាលី ហើយភាសាបាលីនេះចាត់ជាវិជ្ជាមួយដែលកូនសិស្សត្រូវប្រឡងដែរ ។

* * *

## អំពីភាពយន្តរាមកេរ្តិ៍

កាលពីខែណូវែម្ប្រ៍ ១៩៣៩ នោះ នៅក្រុងភ្នំពេញមានលេងកុន ១ ខ្សែល្អមើលណាស់ នៅមន្ទីរលេងកុន ។ គេលេងពីរឿងរាមាយណៈ

ឬកមកេរ្តិ៍ ។ ឯកងទ័ពស្វា នោះគេយកមនុស្សលេងជំនួសដោយពាក់មុខស្វា តាត់ជាកងទ័ព ១ លេងកុនទំនងនេះ ធ្វើឲ្យយើងនឹកឃើញល្ខោនខ្មែរដែលមានពាក់មុខស្វា ប៉ុន្តែរឿងរ៉ាវដែលគេលេងនោះមិនបានលេងតាមទំនងក្នុងរឿងរាមាយណៈជាភាសាសំស្ក្រឹត ឬដែលប្រែមកជារឿងភមកេរ្តិ៍នោះទេ ។ បណ្តារឿងរ៉ាវដែលល្អមើលណាស់នោះត្រង់ដែលហនុមានបាចទឹកសមុទ្រដោយកន្ទុយ ហើយយកកន្ទុយធ្វើជាកំពែងខ្ពស់ការពារព្រះរាមនឹងព្រះលក្ខណ៍ ហើយហនុមានដំណែងជាក្រពើចម្លងមហាសមុទ្រ ។

ប្រសិនបើយើងមានឱកាសល្មមប្រែរឿងរាមាយណៈរបស់ឥណ្ឌាខាងត្បូងមកជាខ្មែរបាន យើងក៏នឹងប្រែផ្សាយដល់អ្នកមើលទស្សនាវដ្តីនេះមិនខាន ។